# ជីអំពុក

សន្លឹកព័ត៌មាន

## តើជីអំពុកជាអ្វី?

**ជីអំពុក**គឺជាល្បាយពិសេសនៃសារធាតុធម្មជាតិផ្សំឡើងដោយរុក្ខជាតិ និងសត្វ។ ដំណើរការនៃជីអំពុកគឺវាធ្វើឲ្យរលួយសារធាតុ សម្ងាប់សរីរាង្គអាក្រក់ ហើយបំផ្លាញចោលនូវគ្រាប់រុក្ខជាតិតូចតាចឥតប្រយោជន៍។ ជីអំពុកអាចដាក់បន្ថែមទៅក្នុងដីដើម្បីជួយបង្កើននូវ**សារធាតុធម្មជាតិសំរាប់ដី។**

ពេលណាសារធាតុធម្មជាតិក្លាយទៅជាជីអំពុក វាជួយធ្វើឲ្យដីមានជីល្អ — វាបន្ថែមនូវជីវជាតិធ្វើឲ្យលូតលាស់ ជួយផ្ទុកទឹក ឲ្យមានខ្យល់ចេញចូល ហើយធ្វើឲ្យរចនាសម្ព័ន្ធរបស់ដីបានកាន់តែល្អប្រសើរឡើង។ ត្រូវធ្វើសារធាតុធម្មជាតិឲ្យក្លាយទៅជាជីអំពុកជាមុនសិន មុននឹងលោកអ្នកអាចយកវាទៅដាក់នៅតាមទីចំការ ឬសួនច្បាររបស់លោកអ្នក។

ជីអំពុកកើតឡើងនៅក្នុងដីតាមធម្មជាតិ។ គេអាចបង្កើតជីអំពុកនៅតាមទីចំការដោយប្រើកំទេចដំណាំ ហើយនិងសារធាតុផ្សេងទៀតនៅក្នុងប្រព័ន្ធធ្វើជីអំពុកដែលរៀបចំល្អ។



## ប្រភេទនៃជីអំពុក

### ជីអំពុកធ្វើពីកាកសំណល់ការបណ្តុះផ្សិតពីកំទេចចំបើង

ជីនេះធ្វើឡើងដោយសារធាតុផ្សិត សំរាមបសុបក្សី ជីលាមកសេះ ចំបើងស្រូវលាលី និងសារធាតុម្នាងសិលា (gypsum)។ វាមានពេញទៅដោយជីវជាតិធ្វើឲ្យលូតលាស់កំរិតខ្ពស់ ហើយជួយធ្វើឲ្យរចនាសម្ព័ន្ធដីបានល្អប្រសើរឡើង។

### ជីអំពុកធ្វើពីសារធាតុធម្មជាតិក្នុងសួន

ជីទាំងនេះកើតចេញពីគល់ឈើ មែកដើម ស្លឹកឈើ និងកំទេចស្មៅកាត់។ វាជួយផ្ទុកទឹកនៅក្នុងដី ហើយជួយធ្វើឲ្យរចនាសម្ព័ន្ធដីបានល្អប្រសើរឡើង។

### ជីអំពុកធ្វើពីសារធាតុកាកសំណល់ក្នុងផ្ទះ

អាចធ្វើចេញពីរបស់ទាំងឡាយដូចជានំប៉័ង សំបុកស៊ុត សំរាមក្នុងសួន សារធាតុក្នុងសួន កាកសំណល់បន្លែ និងផ្លែឈើ។ វាជាជីវជាតិធ្វើឲ្យលូតលាស់កំរិតខ្ពស់ ហើយជួយធ្វើឲ្យរចនាសម្ព័ន្ធដីបានល្អប្រសើរឡើង។

### ជីអំពុកធ្វើពីសារធាតុជីវរឹង (Bio-Solid)

គឺជាសារធាតុស្ងួតរឹងកើតចេញពីកាកសំណល់ច្រោះតាមប្រព័ន្ធលូទឹកស្អុយ។ វាលាយជាមួយដី និងសារធាតុសរីរាង្គផ្សេងទៀត ហើយក្លាយទៅជាជីអំពុក។ ជីនេះមានជីវជាតិធ្វើឲ្យលូតលាស់កំរិតខ្ពស់ណាស់។

HAWKESBURY NEPEAN CATCHMENT MANAGEMENT AUTHORITY

NSW DEPARTMENT OF PRIMARY INDUSTRIES

# ជីអំពុក

## ការទិញជីអំពុក

លោកអ្នកអាចទិញជីអំពុកទាំងបាវបានពីកន្លែងបណ្តុះកូនរុក្ខជាតិ (nursery) កន្លែងលក់គ្រឿងប្រដាប់ប្រើប្រាស់ក្នុងសួន អ្នកជួញដូរនៅទីជនបទ ឃ្លាំងសាលាក្រុង (council depots) និងកន្លែងលក់ដូរជីអំពុក។

ប្រសិនបើលោកអ្នកចង់ទិញជីអំពុកច្រើន លោកអ្នកអាចទិញជីនេះបានពីអ្នកផ្គត់ផ្គង់ជីអំពុក និងពីទីកន្លែងធ្វើជីអំពុក។ ជីអំពុកទាំងនេះគ្រប់គ្រងដោយសាលាក្រុងខ្លះ និងអ្នកលក់ដូរជីអំពុក។ លោកអ្នកអាចរកឃើញព័ត៌មានលំអិតរបស់គេនៅក្រោមចំណងជើង ‘Landscape Supplies’ ក្នុងសៀវភៅរាយលេខទូរស័ព្ទ (telephone directory)។




ពេលណាទិញជីអំពុក សូមរកមើលរូបសញ្ញានៃគុណភាពកំរិតខ្នាតអូស្ត្រាលីនៅពីលើត្រាបាវ។

### គុណភាពតាមកំរិតខ្នាតអូស្ត្រាលី

ជីអំពុកទាំងអស់ដែលលោកអ្នកទិញ ត្រូវឲ្យសមស្របតាមគុណភាពកំរិតខ្នាតអូស្ត្រាលី (Australian Standards AS 4454) សំរាប់ជីអំពុកវត្ថុធាតុជួយតម្រូវលក្ខណៈដី ដើមឈើ និងឫសឈើរលួយ។ រូបសញ្ញានៃគុណភាពកំរិតខ្នាតអូស្ត្រាលីនឹងមានដាក់នៅពីលើត្រាបាវ។



លោកអ្នកអាចទិញជីអំពុកបាន២យ៉ាង:

### ១. ជីអំពុកវត្ថុធាតុជួយតម្រូវលក្ខណៈដី

នេះគឺជាជីអំពុកល្អិតៗដែលអាចយកទៅលាយជាមួយដីផ្នែកលើ។ វាបញ្ចេញនូវជីវជាតិធ្វើឲ្យលូតលាស់សន្សឹមៗ ជួយផ្ទុកទឹក ហើយជួយធ្វើឲ្យរចនាសម្ព័ន្ធដីបានល្អប្រសើរឡើង។

### ២. ជីអំពុកដើមឈើ និងឫសឈើរលួយ

នេះគឺជាជីអំពុកដុំធំគគ្រើមៗដែលអាចដាក់នៅពីលើដីផ្នែកលើ។ ជីនេះជួយឲ្យដីជក់ទឹក ហើយបញ្ឈប់រុក្ខជាតិតូចតាចឥតប្រយោជន៍កុំឲ្យដុះលូតលាស់បាន។

© NSW DPI February 2007

ដើម្បីទទួលយកព័ត៌មានបន្ថែមទៀតសូមទាក់ទង

Gosford Horticultural Institute
NSW Department of Primary Industries
Locked Bag 26 Gosford NSW 2250
ph: 02 4348 1913 fax: 02 4348 1910